Khmer | ភាសាខ្មែរ

# មជ្ឈមណ្ឌលថែទាំបឋមជាអាទិភាព

## តើអ្នកត្រូវការទៅជួបវេជ្ជបណ្ឌិតជាបន្ទាន់ទេ?

មជ្ឈមណ្ឌលថែទាំបឋមជាអាទិភាព (PPCCs) ផ្តល់ជូនការព្យាបាលដោយឥតគិតថ្លៃសម្រាប់អ្នកដែលរងរបួស ឬជំងឺបន្ទាន់។

វេជ្ជបណ្ឌិត PPCC នឹងជួយអ្នកឱ្យទទួលបានការព្យាបាលដែលអ្នកត្រូវការបានលឿនជាងនៅផ្នែកសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យ។

ពួកគេអាចព្យាបាលស្ថានភាពនានាដូចជាការឆ្លងមេរោគស្រាល របួសតិចតួច ការគ្រេច ឬថ្លោះ ឬសង្ស័យថាបាក់ឆ្អឹង។ សេវាកម្ម PPCC រួមមាន រោគវិទ្យា វិទ្យុសកម្ម និងឱសថស្ថាន។

**ប្រសិនបើអ្នករងរបួស ឬមានជំងឺធ្ងន់ធ្ងរ សូមទូរសព្ទទៅលេខសូន្យបីដង (000)។ ប្រសិនបើអ្នកមិនត្រូវការការថែទាំបន្ទាន់ទេ សូមធ្វើការណាត់ជួបជាមួយវេជ្ជបណ្ឌិតធម្មតារបស់អ្នក។**

សេវាកម្ម PPCC គឺមិនគិតថ្លៃសម្រាប់មនុស្សគ្រប់រូបដែលមាន ឬគ្មានកាត Medicare។

អ្នកបកប្រែភាសាផ្ទាល់មាត់មាននៅ PPCCs។ ទូរសព្ទទៅសេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ TIS National តាមលេខ 131 450។

សូមចូលមើល **Better Health Channel** សម្រាប់ទីតាំង និងព័ត៌មានបន្ថែម៖
betterhealth.vic.gov.au/priority-primary-care-centres

TIS TRANSLATING AND INTERPRETING SERVICE

phn VICTORIAN-TASMANIAN ALLIANCE
An Australian Government Initiative

VICTORIA State Government